USAID
FROM THE AMERICAN PEOPLE

អេម អេស អេម អ៊ី កម្ពុជា
Cambodia MSME
Micro, Small and Medium Enterprise Strengthening Project

# បច្ចេកទេស
# ចិញ្ចឹមឃ្មុំធំ

## ដោយការដាក់បង្គង និងគន្លឹះ
## សំខាន់ៗ នៃការធ្វើអាជីវកម្មទឹកឃ្មុំ



# ឃ្មុំធំ និងអត្ថប្រយោជន៍

## ឃ្មុំធំ





## អត្ថប្រយោជន៍



ដំណើរលំអងជួយបង្កើនទិន្នផល
ដំណាំ ឈើហូបផ្លែ...



ទឹកឃ្មុំ-ក្រមួន ផ្ដល់ជាចំណូល
ដល់ប្រជាជនតាមជនបទ



តម្លៃជាឱសថជួយដល់សុខភាព



រក្សាឃ្មុំ រក្សាព្រៃដុះល្អ ថែរក្សាបរិស្ថាន



- ក្រៅពីសត្វឃ្មុំធំ មានឃ្មុំច្រើនប្រភេទផ្សេងទៀតដូចជា ឃ្មុំព្រួត, ឃ្មុំកប៉ុកអាចម៍ឆ្កែ, ឃ្មុំផ្ទិត, ឃ្មុំម្រោម។
- ប្រភេទឈ្មោះនៃឃ្មុំអាចត្រូវបានគេហៅ ខុសៗគ្នាទៅតាមតំបន់។

# សកម្មភាពល្អ មិនល្អ និងផលប៉ះពាល់ទៅលើឃ្មុំធំ

| សកម្មភាពល្អដើម្បីការពារឃ្មុំធំ (✓) | សកម្មភាពមិនល្អដែលប៉ះពាល់ដល់សត្វឃ្មុំ (✗) | ផលប៉ះពាល់ |
|---|---|---|
|  ការប្រើប្រាស់គុបផ្សែង   |  ការប្រើប្រាស់ថ្នាំពុលចាញ់សម្លាប់សត្វឃ្មុំ |  សម្លាប់សត្វឃ្មុំ  ទឹកឃ្មុំមានជាតិពុល |
| |  ការគប់ដុំថ្មទៅលើសម្បុកឃ្មុំ |  រំខានដល់សត្វឃ្មុំ ហើយវានឹងហើរចេញពីសម្បុកលែងត្រឡប់មកវិញ |
| |  ការដុតសម្លាប់សត្វឃ្មុំ |  ឃ្មុំងាប់ |
|  កាត់យកតែក្បាលទឹក |  ការយកសម្បុកឃ្មុំទាំងមូល (កូនឃ្មុំ + ក្បាលទឹក) |  ឃ្មុំហើរចេញពីសម្បុក បរិមាណទឹកឃ្មុំថយចុះ |
|  ថែរក្សាជម្រកសត្វឃ្មុំ (ប្រភពទឹក ផ្កា...។ល។) |  ការកាប់មែកឈើ ឬដើមឈើនៅពេលយកឃ្មុំ |  បាត់បង់ជម្រកសត្វឃ្មុំ |

# ការចិញ្ចឹមឃ្មុំធំដោយដាក់បង្គង

## អត្ថប្រយោជន៍នៃការដាក់បង្គង



សិទ្ធិនៃការគ្រប់គ្រង



ងាយស្រួលចូលទៅដល់ / ងាយស្រួលថែរក្សា





ងាយស្រួលដំឡើង និងផ្លាស់ប្តូរទីតាំង ដាក់បង្គងបាន



មានសុវត្ថិភាព (មិនខ្ពស់ដូចដើមឈើ)



ងាយស្រួលយក



ការចិញ្ចឹមឃ្មុំធំដោយដាក់បង្គង គឺជាមុខរបរដ៏សំខាន់មួយរបស់សមាជិកសហគមន៍ ដែលរស់នៅក្បែរ ឬក្នុងតំបន់ព្រៃឈើ។

# របៀបដាក់បង្គង




បង្គងប្រើឈើ២



បង្គងដាក់ភ្ជាប់នឹងដើមឈើរស់



ទីគង់

- ប្រភេទឈើដែលអាចយកមកធ្វើបង្គងឃ្មុំធំ មានដូចជា ដើមត្រសេក ដើមស្មាច់ ដើមបើស ដើមឈើជ័រ ដើមចរកោះ ដើមក្តឈ្លូស ដើមកកោះ ផ្ដុង យាងចោ៉ង ត្រយឹង សិមាន់ ពពេល ព្រីង ច្រមាស់ ដើមឫស្សី (ហាមប្រើដើមក្រាយពីព្រោះវាមានជាតិពុល)។
- យើងធ្វើឱ្យបង្គងនោះរលោង ករណីប្រភេទឈើដែលមានសំបក។
- ផលប្រយោជន៍ទីគង់ **(Tikong)** គឺជួយការពារសម្បុកឃ្មុំធំ ពីទឹកភ្លៀងនៅក្នុងរដូវវស្សា។



# ទីតាំងល្អសម្រាប់ដាក់បង្គង



សម្អាតទីតាំង
សម្រាប់ដាក់បង្គង

តំបន់ព្រៃទាប, ព្រៃស្បាត





ព្រៃលិចទឹក

ប្រភពផ្កាគ្រប់រដូវ





គ្មានសត្វល្អិត
គ្មានអង្ក្រង



- សូមជួយថែរក្សា ការពារបរិស្ថាន និងតំបន់ព្រៃជម្រកឃ្មុំធំឱ្យបានល្អ។
- សូមកុំដាក់បង្គងនៅជិតផ្ទះ ព្រោះអាចគ្រោះថ្នាក់ដោយឃ្មុំទិច។
- ការដាក់បង្គងនៅក្បែរតំបន់អភិវឌ្ឍ កសិកម្មទ្រង់ទ្រាយធំ កាន់តែប្រសើរ។

# របៀបយកឃ្មុំធំប្រកបដោយនិរន្តរភាព

## កាត់យកតែក្បាលទឹក



## ពេលវេលាយកឃ្មុំ



យកឃ្មុំនៅពេលពេញក្បាលទឹក (ក្បាលទឹកពណ៌ស និងរន្ធបិទជិត)



ប្រើគប់ផ្សែង

## សម្ភារប្រើប្រាស់ដើម្បីយកឃ្មុំ

កាំបិតឈើ





ធុងគ្មានជាតិច្រែះ

ថង់ផ្លាស្ទិក





ខ្សែពួរសម្រាប់យួរធុង



- ការថែរក្សាឃ្មុំបានល្អនោះ ពួកគេនឹងផ្តល់ទឹកឃ្មុំជារៀងរាល់រដូវ។
- ប្រសិនបើកាត់យកតែក្បាលទឹក ឃ្មុំនឹងនៅសម្បុកនេះដដែល និងធ្វើក្បាលទឹកថ្មីនៅលើសម្បុកនេះ អ្នកអាចយកបាន៣ដងក្នុងមួយសម្បុក។
- ពេលយកឃ្មុំគប្បីត្រូវធ្វើការជាក្រុម។
- ការយកឃ្មុំមានភាពប្លែកគ្នាតាមតំបន់ និងតាមរដូវការល។

សម្ភារទាំងនេះចាំបាច់ត្រូវតែស្អាត បើមិនដូច្នេះទេ ទឹកឃ្មុំនឹងខូច។

# សកម្មភាពបន្ទាប់ពីប្រមូលផល (ក្រោយពីកាត់យកក្បាលទឹក)

1 សំអាតដៃ និងសម្ភារ ឱ្យបានស្អាត



2 កាត់ក្បាលទឹកជាចំណិតៗ (កុំឱ្យដោយលម្អង និងកូនឃ្មុំ... )



3 ដាក់ក្បាលទឹកដែល កាត់ជាចំណិតចូលទៅ ក្នុងធុងចម្រោះ



3 ប្រើស្បៃស្អាត សម្រាប់ចម្រោះ (ករណីគ្មានធុងចម្រោះ)



4 ទូរសម្ងួត



5 បន្ទប់សម្ងួត



6 ការច្រកដបវេចខ្ចប់






7 នៅលើសម្បកវេចខ្ចប់ គួរបញ្ចូលពត៌មានដូចជា

- ឈ្មោះ និង ទីតាំងសហគមន៍
- ពាក្យឃ្មុំព្រៃ
- គួរមានពណ៌ចម្រុះ



- សម្រាប់ឧបករណ៍សម្ងួត វាអាស្រ័យលើ ធនធានរបស់សហគមន៍។ យើងអាចប្រើទូរសម្ងួត ឬបន្ទប់សម្ងួត ឬប្រើម្តងទាំងពីរ ទៅតាមលទ្ធភាពរបស់សហគមន៍។
- ដៃស្អាត, សម្ភារស្អាត ធ្វើឱ្យទឹកឃ្មុំមានគុណភាពល្អ។



ឃ្មុំធំ គឺជាសត្វដ៏មានប្រយោជន៍បំផុត។ ការចិញ្ចឹម និងថែរក្សាជម្រកសត្វឃ្មុំធំបានល្អ វានឹងជួយផ្ដល់នូវចំណូលបន្ថែមទៀតដល់អ្នក និងគ្រួសារអ្នក។

ដើម្បីជាជំនួយដល់លោកអ្នក នៅក្នុងការធ្វើអាជីវកម្មទឹកឃ្មុំ សូមមើលលើទំព័របន្ទាប់ ដែលនឹងបង្ហាញអ្នកអំពីរបៀបនៃការធ្វើ និងគ្រប់គ្រងអាជីវកម្មទឹកឃ្មុំរបស់លោកអ្នកឱ្យកាន់តែប្រសើរឡើង។


ខ្ញុំឈ្មោះ បងសង្ហា។ ហ្វេ...ថ្ងៃនេះខ្ញុំនឹងចេញពីសម្បុករបស់ខ្ញុំ ទៅកាន់ភូមិក្បែរនេះ ដើម្បីជជែកជាមួយក្រុមបងប្អូនអ្នកយកឃ្មុំ អំពីរបៀបធ្វើអាជីវកម្មទឹកឃ្មុំ ពីព្រោះថា វាកាន់តែកៀករផ្លូវយកឃ្មុំមែនទែនហើយ


ហ្អេ... បងប្រុសបងស្រីទាំងអស់គ្នា...
ខ្ញុំរីករាយណាស់ដែលបានជួបបងបងនៅទីនេះ និង
សូមជម្រាបថា រដូវយកឃ្មុំ ជិតដល់ហើយ អញ្ចឹងហើយ
បងបង សូមរៀបចំសម្ភារ និងត្រៀមខ្លួនណា។
នៅពេលដែលបងមានទឹកឃ្មុំ បងត្រូវ យកវាទៅលក់
អញ្ចឹងវាសំខាន់ណាស់ដែលបងបងត្រូវរក្សាទំនាក់
ទំនង និងកសាងទំនុកចិត្តជាមួយនឹងអ្នកទិញទាំងអស់
នោះណា។ តែត្រូវចាំថា ទឹកឃ្មុំរបស់បងត្រូវតែមាន
គុណភាព និងសុទ្ធល្អហើយបរិមានគ្រប់គ្រាន់។
បើមានបញ្ហាទាក់ទងនឹងគុណភាព បរិមាណផ្គត់ផ្គង់
ទឹកឃ្មុំ...ត្រូវជូនដំណឹង ទៅអ្នកទិញវិញភ្លាម។ អូ...
ខ្ញុំទៅខាងនោះសិន ហើយណា


បងសង្ហាខ្ញុំ សូមប្រាប់បងថា ទោះបីជាដល់មិនទាន់ដល់រដូវ ឬដល់រដូវយកឃ្មុំ បងបង ត្រូវតែរក្សាទំនាក់ទំនងជាមួយ អ្នកទិញឱ្យបានជាប់លាប់ណា អើ... ត្រូវប្រាប់គាត់អំពីផែនការយកឃ្មុំរបស់ក្រុមបង ត្រូវសួរគាត់វិញអំពីតម្រូវការទាក់ទងនឹងគុណភាព បរិមាណ... អ៊ីចឹងទៅអ្នកទិញរៀបចំផែនការរបស់គាត់ទាន់ពេល។ ឧទាហរណ៍ ប្រសិនបើមិន ទាក់ទងអ្នកទិញឱ្យបានជាប់លាប់ទេ ជួនកាលពេលយកទឹកឃ្មុំទៅលក់ គេអត់ទាន់មានលុយឱ្យយើង ឬគេទិញពីកន្លែងផ្សេង ឬក៏គេអត់ទិញហ្មង


ហ្អេបងប្រុស មុនពេលបងចេញទៅ ខ្ញុំមានរឿងមួយចង់ប្រាប់បងថា បងត្រូវមើលទីផ្សា ណាដែលគេទិញទឹកឃ្មុំដែលមានគុណភាពល្អ។ ប៉ុន្តែត្រូវចាំថា ទឹកឃ្មុំរបស់បងបងនោះ ជាទឹកឃ្មុំសុទ្ធ ចម្រោះបានស្អាត និងវេចខ្ចប់បានត្រឹមត្រូវ។ ខ្ញុំទៅផ្សារជាមួយបងបងដែរណា។


នៅពេលដែលបងអាចផ្គត់ផ្គង់តម្រូវការរបស់អ្នកទិញបាន (បរិមាណ គុណភាព...) សូមកុំភ្លេចប្រាប់អ្នកទិញនោះ ជួយណែនាំអ្នកទិញ ផ្សេងៗទៀតឱ្យជួយទិញផង អញ្ចឹងទៅបងបង អាចពង្រីកទីផ្សារ ហើយជួយឱ្យក្រុមយកឃ្មុំបងបង អាចលក់ទឹកឃ្មុំបានច្រើនជាងនេះទៀត។ ឥឡូវខ្ញុំត្រឡប់ទៅសម្បុកវិញហើយ។
ឃ្មុំព្រៃ
ឃ្មុំព្រៃ


បងសង្ហាខ្ញុំ សូមជំរាបជូនបងបងថា ឃ្មុំខ្ញុំនេះ នៅតាមរដូវទេ និង មុខរបរទឹកឃ្មុំ ក៏មិនមែន ជាមុខរបរទី១ដែរ ហ្អេ ហ្អេ តែបងបងកុំមើលងាយណា។ មុខរបរទឹកឃ្មុំនេះ អាចផ្តល់ជាចំណូល បន្ថែមទៀត បើគ្រប់គ្រងវាបានល្អ។ មុខរបរទឹកឃ្មុំនេះ ជាមុខរបរប្រសើរមួយ ពីព្រោះថា បងបងមិនចាំបាច់ចំណាយទុនធំនោះទេ ជាពិសេស បងបងមិនបាច់យកលុយមកវិនិយោគជាមួយ បងឃ្មុំខ្ញុំនេះទេ។ អ្វីដែលបងត្រូវធ្វើ គឺថែរក្សាឃ្មុំ និងព្រៃជម្រកឃ្មុំឱ្យបានល្អទៅ និងប្រើប្រាស់ វិធីសាស្ត្រយកឃ្មុំដោយនិរន្តរភាពណា។


ដើម្បីធ្វើឱ្យមុខរបរនេះដំណើរការយូរអង្វែង និង
ជឿជាក់បាន បងបងត្រូវគ្រប់គ្រងក្រុមយកឃ្មុំ
របស់បង និងធានាឱ្យប្រាកដថា ក្រុមរបស់
បងបង ធ្វើលក្ខន្តិកៈក្រុមឃ្មុំ និងយកវាដោយ
និរន្តរភាព បញ្ជាក់ទីតាំងប្រមូលឱ្យបានច្បាស់
លាស់ ឈ្មោះអ្នកប្រមូល ចម្រោះឱ្យបានត្រឹមត្រូវ។
សូមកត់សំគាល់ថាប្រសិនបើមានអ្នកណាម្នាក់ពីក្រុមយកឃ្មុំ
របស់បង លក់ទឹកឃ្មុំដែលមិនសុទ្ធ និងមានលាយស្ករទៅឱ្យ
អ្នកទិញ នោះពួកគេនឹងឈប់ទិញទឹកឃ្មុំពីបង និងក្រុមយក
ឃ្មុំរបស់បងបង ហើយពួកគេអាចនិយាយមិនល្អពីសហគមន៍
របស់បង ធ្វើឱ្យខូចទីផ្សារទាំងមូលតែម្តង។
អូ.អូ. ខ្ញុំភ្លេច ប្រាប់បងបងរឿងមួយហ្នឹង ឥឡូវខ្ញុំត្រឡប់ទៅ
សម្បុករបស់ខ្ញុំវិញហើយ។


បងសង្ហាខ្ញុំដឹងថា បងបងរវល់ណាស់ជាមួយនឹងការងារផ្សេងៗទៀត ដូចជា ធ្វើស្រែ ដាំដំណាំ... ដូច្នេះខ្ញុំគិតថា វាល្អដែរប្រសិនបើបងបងមានអ្នកទទួលជួយលក់ ដូចជាបងបង អាចលក់វាទៅឱ្យអ្នកទិញទឹកឃ្មុំនៅក្នុងតំបន់របស់បងបង អ៊ីចឹងបងសល់ពេលធ្វើការងារផ្សេងៗទៀត និងមានពេលនៅជាមួយគ្រួសារផង។ អ្នកទិញហ្នឹង គាត់បានចំណេញខ្លះដែរនៅពេលលក់ទឹកឃ្មុំបន្ត ប៉ុន្តែគាត់ហ្នឹង ក៏ត្រូវធ្វើការងារច្រើនដែរណា ដូចជា ត្រូវទាក់ទងដឹកជញ្ជូន។ល។ អ៊ីចឹង សរុបមកវិញ វាចំណេញទាំងសងខាងទេណាបង។
ឃ្មុំព្រៃ

USAID
FROM THE AMERICAN PEOPLE

អេម អេស អេម អ៊ី កម្ពុជា
Cambodia MSME
Micro, Small and Medium Enterprise Strengthening Project





**ទំនាក់ទំនងព័ត៌មាន**

គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមកម្ពុជា
បន្ទប់ ៥៨៨ អគារ ភ្នំពេញ សិនធីរ កែងវិថី ២៧៤/៣ ទន្លេបាសាក់ ភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ២២២ ៤៩៦
ទូរសារ: (៨៥៥) ២៣ ៣៣៣ ៤៩៥
គេហទំព័រ: **www.cambodiamsme.org**

**សេចក្តីបញ្ជាក់:**

ទស្សនៈរបស់អ្នកនិពន្ធដែលបង្ហាញក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ឬរដ្ឋាភិបាលអាមេរិកនោះឡើយ ។

គម្រោង អេម អេស អេម អ៊ី កម្ពុជា កំពុងអនុវត្តដោយអង្គការ ឌី អេ អាយ (www.dai.com)